រូបសញ្ញាក្រុមហ៊ុន (Singapore Techologies Telemedia) ការផ្សាយពតិមាន

# ក្រុមហ៊ុនអេសធីតេឡេមេឌា (ST Telemedia) ផ្តល់ម៉ាស៊ីនស្កេនកម្តៅរកអ្នកកើតជំងឺផ្តាសាយ A/H1N1 ថ្មីមួយ សំរាប់ចំពាក់នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ

**ម៉ាស៊ីនស្កេនកម្តៅថ្មីនេះ គាំទ្រការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការរីករាលដាលជាសាកលនៃជំងឺ A/H1N1**

នៅទីក្រុងភ្នំពេញ ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៩នេះ: ដើម្បីឆ្លើយតបទៅនឹងសំណើររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុន Singapore Techologies Telemedia ដែលជាក្រុមហ៊ុនគមនាគមន៏ពតិមាននាំមុខមួយហើយធ្វើប្រតិបត្តិការនៅតំបន់អាស៊ីប៉ាស៊ីភិច អាមេរិក និង អ៊ឺរុប បានផ្តល់នូវម៉ាស៊ីនស្កេនកម្តៅរកអ្នកកើតជំងឺ A/H1N1ថ្មីមួយ សំរាប់ប្រើប្រាស់នៅឯសាលដំណើរមកដល់នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ ម៉ាស៊ីនថ្មីនេះ ផ្តល់នូវការគាំទ្រយ៉ាងសំខាន់ចំពោះសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលជាសាកល នៃជំងឺ A/H1N1នៅក្នុងប្រទេស។

នៅឯពិធីមួយនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញនៅថ្ងៃនេះ ម៉ាស៊ីនស្កេនកម្តៅថ្មីនេះ ត្រូវបានប្រគល់ជូនឯកឧត្តមបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលប្រទេសកម្ពុជា ដោយ Mrs Kuan Kwee Jee អនុប្រធានក្រុមហ៊ុនអេសធីតេឡេមេឌា (ST Telemedia) ហើយ មានការដឹងលឺដោយឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំប្រទេសកម្ពុជា លោកជំទាវ Tan Yee Woan។ នៅឯពិធីនោះ ក៏មានវត្តមានមន្ត្រីជាន់ខ្ពស់ផ្សេងៗមកពីស្ថាប័នរដ្ឋាភិបាលកម្ពុជានិងមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀតមកពីក្រុមហ៊ុនអេសធីតេឡេមេឌា (ST Telemedia) និងក្រុមហ៊ុន អឹមហ្វូន ខាំផានី អិលធីឌី (Mfone Company Ltd.)។

Mr. Lee Theng Kiat ដែលជាប្រធាន ក្រុមហ៊ុន អេសធីតេឡេមេឌា (ST Telemedia) បានមានប្រសាសន៍ថា ក្រុមហ៊ុន អេសធីតេឡេមេឌា (ST Telemedia) មានការពាក់ព័ន្ធគំរោងអភិវឌ្ឍន៏សហគមន៏ចាប់តាំងពីឆ្នាំ ២០០៥មកម្លេះ។ អំណោយម៉ាស៊ីនស្កេនកម្តៅថ្មីនេះ គឺជាការបង្ហាញនូវការប្តេជ្ញាចិត្តរបស់យើងបន្ថែមទៀត ដើម្បីធ្វើឱ្យមានការជោគជ័យសុខមាលភាពរបស់ប្រជាជនកម្ពុជា។

ម៉ាស៊ីនស្កេនកម្តៅថ្មីនេះ ដែលមានតំលៃប្រហែល៧៥ ០០០ ដុល្លារអាមេរិក (ប្រហែល៣១០ ៩៥០ ០០០ រៀល) បានប្រើប្រាស់បច្ចេកវិជ្ជាអុបទិចអេឡិចត្រូនិចនាំមុខសំរាប់ការស្កេនចំនួនមនុស្សច្រើនទាន់ពេលឆាប់រហ័ស។ ដើម្បីផ្តល់ជំនាញដល់មន្ត្រីកម្ពុជាសំរាប់ប្រតិបត្តិការប្រពន្ធ័ម៉ាស៊ីននេះ ក្រុមហ៊ុនអេសធីតេឡេមេឌា (ST

Telemedia) បានរៀបចំឱ្យមានវិស្វករពីរនាក់មកពីក្រុមហ៊ុនផលិតម៉ាស៊ីនស្កេនពីសិង្ហបុរីមកទីក្រុងភ្នំពេញ ដើម្បី ផ្តល់នូវការបណ្តុះបណ្តាលនៅហ្នឹងកន្លែង។

ក្រុមហ៊ុនអេសធីតេឡេមេឌា (ST Telemedia) បានចូលមកក្នុងទីផ្សារកម្ពុជាតាំងពីឆ្នាំ ២០០៧មកម្លេះ តាមរយៈភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុន Shenington Investment ដែលកាន់កាប់ក្រុមហ៊ុន Mfone Company Limited ដែលជាក្រុមហ៊ុនទូរសព្ទចល័តធំបំផុតទីពីរនៅប្រទេសកម្ពុជា។

**ពត៌មានបន្ថែមអំពីក្រុមហ៊ុន Singapore Techologies Telemedia**

ក្រុមហ៊ុន Singapore Techologies Telemedia (ST Telemedia) ធ្វើការវិនិយោគ និង គ្រប់គ្រងនូវរបស់កើតថ្មីរបស់ក្រុមហ៊ុនគមនាគមន៍ពត៌មានទូទាំងពិភពលោក។ សមត្ថភាពរបស់ក្រុមហ៊ុន (ST Telemedia) គឺក្នុងការផ្តល់សេវាគមនាគមន៍ចល័តនិងអ៊ិនធឺណែតទូទាំងពិភពលោក។ ក្រុមហ៊ុន ST Telemedia ធ្វើប្រតិបត្តិការនានា នៅក្នុងតំបន់អាស៊ីប៉ាស៊ីភិច អាមេរិក និង អ៊ឺរ៉ុប។ ក្រុមហ៊ុនសំខាន់ៗរបស់ក្រុមហ៊ុន ST Telemedia រួមមាន ក្រុមហ៊ុន Global Crossing ក្រុមហ៊ុន TeleChoice និង ក្រុមហ៊ុន Asia Mobile Holdings ដែលមានសិទ្ធិកាន់កាប់មួយផ្នែកនៅក្នុងក្រុមហ៊ុន StarHub និង ក្រុមហ៊ុន Shenington Investment ដែលបង្វិលការកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុនទូរគមនាគមន៍ឡាវ (Lao Telecommunication Company) និងក្រុមហ៊ុន អឹមហ្វូន (Mfone Company) នៅក្នុងប្រទេសកម្ពុជា។ ទ្រព្រសម្បត្តិ និង សមត្ថភាពរួមរបស់ក្រុមរបស់ក្រុមហ៊ុននានា បានដាក់នៅលើក្រុមហ៊ុន (ST Telemedia)តែមួយ ដើម្បីផ្តល់ដែនទូលំទូលាយខាងជំនាញនិងដំណោះស្រាយនៅក្នុងការភ្ជាប់ទំនាក់ទំនងជាសាកល សេវាចល័តសំដៅកន្លែងណាមួយ និងសេវាវិស្វកម្មបណ្តាញ។ សំរាប់ពត៌មានបន្ថែមពីក្រុមហ៊ុន ST Telemedia សូមមើលវិបសាយ www.sttelemedia.com

**ទំនាក់ទំនងពត៌មាន**

Ms Melinda Tan
Singapore Technologies Telemedia
ទូរសព្ទ: +65 6723 8690
អ៊ីមែល: melinda_tan@sttelemedia.com